**ចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

លេខសំណុំរឿង៖ ០០២-១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ៖ ការិយាល័យសហព្រះរាជអាជ្ញា

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ ភាសាអង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១១

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 26-Jan-2011, 10:53
CMS/CFO: Kauv Keoratanak

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬអង្គជំនុំជម្រះ៖ **សាធារណៈ/Public**

ឋានៈនៃចំណាត់ថ្នាក់ឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាលើសំណើបន្ទាន់របស់មេធាវីការពារក្ដីរបស់ អៀង ធីរិទ្ធ និង នួន ជា សុំឲ្យបញ្ជាក់ថ្ងៃផុតកំណត់**

---

| **ភាគីដាក់ឯកសារ៖** | **ដាក់ជូន៖** | **ចម្លងជូន៖** |
|---|---|---|
| **សហព្រះរាជអាជ្ញា** | **អង្គជំនុំជម្រះសាលាដំបូង** | **ជនជាប់ចោទ** |
| ជា លាង | ចៅក្រម **និល ណុន** ជាប្រធាន | **នួន ជា** |
| Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | **អៀង សារី** |
| | ចៅក្រម **យ៉ា សុខន** | **អៀង ធីរិទ្ធ** |
| | ចៅក្រម Jean-Marc LAVERGNE | **ខៀវ សំផន** |
| | ចៅក្រម **ធូ មណី** | |

សំណុំរឿងលេខៈ ០០២/១៩-០៩-២០០៧-អវតក/អជសដ

**សហមេធាវីនាំមុខតំណាង**
**ដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីការពារក្តី**
សុន អរុណ
Michael PESTMAN
Victor KOPPE
អាង ឧត្តម
Michael G.
KARVANVAS
ផាត់ ពៅស៊ាង
Diana ELLIS
ស សុវាន
Jacques VERGES
Phillipe GRECIANO

*សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ*

## I. សេចក្តីផ្តើម

១. នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះបានចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អៀង ធីរិទ្ធ និង នួន ជា ជំទាស់នឹងដីកាដំណោះស្រាយ("សាលដីកាលើបណ្តឹងឧទ្ធរណ៍")[1]។ នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១ អៀង ធីរិទ្ធ និង នួន ជា (ហៅរួមថា "ក្រុមមេធាវីការពារក្តី"បានដាក់"សំណើបន្ទាន់របស់មេធាវីការពារក្តីសុំឱ្យបញ្ជាក់ពីថ្ងៃកំណត់"("សំណើ")[2]។ សំណើរបស់ក្រុមមេធាវីការពារក្តីស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចេញដីកាសម្រេច ថាពេលវេលាផុតកំណត់ ដែលត្រូវបានដាក់ដោយវិធាន៨០ និង ៨៩ គឺគិតចាប់ពីថ្ងៃដែលអង្គបុរេជំនុំជម្រះផ្តល់សំអាងហេតុជាមូលដ្ឋានទៅលើសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន[3]។ សហព្រះរាជអាជ្ញាសូមជំទាស់ទៅនឹងសំណើរបស់មេធាវីការពារក្តី តាមហេតុផលលម្អិតដូចខាងក្រោម។

## II. អង្គជំនុំជម្រះសាលាដំបូងពុំគួរកែប្រែកាលបរិច្ឆេទ ដែលការផុតកំណត់នៃការដាក់បញ្ជីសាក្សី អនុលោមតាមវិធាន ៨០ ចាប់ផ្តើមនោះឡើយ

២. វិធាន ៨០ នៃវិធានផ្ទៃក្នុង ចែងលម្អិតអំពីពេលវេលាក្នុងការដាក់បញ្ជីសាក្សីរបស់ភាគី និងចែងថាសហព្រះរាជអាជ្ញាត្រូវដាក់បញ្ជីសាក្សីរបស់ខ្លួនក្នុងរយៈពេល ១៥ ថ្ងៃ គិតចាប់ពីថ្ងៃដីកាបញ្ជូនរឿងទៅជំនុំជម្រះចូលជាស្ថាពរ ចំណែកភាគីដទៃទៀតត្រូវដាក់បញ្ជីសាក្សីបន្ថែមក្នុងរយៈពេល ១៥ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីបញ្ជីរបស់សហព្រះរាជអាជ្ញា"[4]។ នៅក្នុងដីកា

---

[1] អង្គបុរេជំនុំជម្រះ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី ១៣ ខែមករា ឆ្នាំ២០១១ (បន្ទាប់ពីនេះ "សាលដីកាលើបណ្តឹងឧទ្ធរណ៍")។

[2] ក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ និង នួន ជា, សំណើបន្ទាន់របស់មេធាវីការពារក្តីសុំឱ្យបញ្ជាក់ពីថ្ងៃកំណត់, ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១ (បន្ទាប់ពីនេះ "សំណើរបស់ក្រុមមេធាវីការពារក្តី")។

[3] សំណើរបស់ក្រុមមេធាវីការពារក្តី កថាខណ្ឌ ៨ ។

[4] វិធានផ្ទៃក្នុង អ.វ.ត.ក, វិធាន ៨០ (១-២)។

សម្រេចរបស់ខ្លួនចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ពេលវេលាអនុលោមតាមវិធាន ៨០ ចាប់ផ្តើមគិតចាប់ "ពីថ្ងៃសុក្រ ទី១៤ ខែមករា ឆ្នាំ២០១១ ជាថ្ងៃដែលក្រឡាបញ្ជីបានទទួលសំណុំរឿងជាផ្លូវការពីអង្គបុរេជំនុំជម្រះ"[5]។ ដោយយោងទៅលើការបញ្ជាក់ច្បាស់លាស់របស់អង្គជំនុំជម្រះសាលាដំបូងស្តីពីបញ្ហានេះ ឧទាហរណ៍ដូចជា ការបញ្ជាក់ថាពេលវេលាគិតចាប់ពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១ សំណើរបស់មេធាវីការពារក្តីស្នើសុំការបញ្ជាក់អំពីថ្ងៃផុតកំណត់ជាធរមានគឺពុំពាក់ព័ន្ធ។

៣. ទោះជាយ៉ាងណាក្តី អំណះអំណាងរបស់មេធាវីការពារក្តី ដែលថាផលប្រយោជន៍របស់ខ្លួននឹងត្រូវប៉ះពាល់ ប្រសិនបើខ្លួនពុំមានសាលដីកាពេញលេញរបស់អង្គបុរេជំនុំជម្រះនៅមុនពេលចងក្រងបញ្ជីសាក្សីរបស់ខ្លួន[6] គឺពុំមានមូលដ្ឋានច្បាស់លាស់ និងគួរត្រូវបានអង្គជំនុំជម្រះសាលាដំបូងបដិសេធ។ ដូចដែលបានកែតម្រូវតាមរយៈសាលដីការបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ដីកាដំណោះស្រាយ មានចែងច្បាស់អំពីបទចោទមកលើជនជាប់ចោទ និងពិភាក្សាល្អិតល្អន់អំពីភស្តុតាង និងច្បាប់នានាដែលជាសំអាងក្នុងការចោទប្រកាន់[7]។ មេធាវីការពារក្តីពុំបានពន្យល់ថាតើ លទ្ធភាពរបស់ខ្លួនក្នុងការចងក្រងបញ្ជីសាក្សីនឹងត្រូវប៉ះពាល់យ៉ាងដូចម្តេចឡើយ នៅពេលខ្លួនពុំអាចពិនិត្យមើលសំអាងហេតុជាក់លាក់ដែលជាមូលដ្ឋាននៃការសម្រេចរបស់អង្គបុរេជំនុំជម្រះលើមូលដ្ឋាន*តាមយុត្តាធិការ*នៃបណ្តឹងឧទ្ធរណ៍។ ប្រសិនបើគេនិយាយឲ្យពីរោះស្តាប់បន្តិច អំណះអំណាងនេះជាអំណះអំណាងហួសព្រំដែន

---

[5] អង្គជំនុំជម្រះសាលាដំបូង, ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ, ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១។

[6] សំណើរបស់ក្រុមមេធាវីការពារក្តី, កថាខណ្ឌ ៦។

[7] សូមមើលសាលដីកាលើបណ្តឹងឧទ្ធរណ៍, កថាខណ្ឌ ៦-៧ (ដែលបានបដិសេធមូលដ្ឋានទាំងអស់នៃបណ្តឹងឧទ្ធរណ៍របស់ នួន ជា និងមូលដ្ឋានខ្លះនៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ លើកលែងតែផ្នែកខ្លះនៃមូលដ្ឋានទី ៤)។ សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថាក្រុមមេធាវីការពារក្តីមានពេលវេលាជាច្រើនខែក្នុងការពិនិត្យដីកាដំណោះស្រាយ ដែលត្រូវបានកែប្រែបន្តិចបន្តួចតាមរយៈសាលដីការបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១។

ប៉ុន្តែបើនិយាយឲ្យអាក្រក់ស្តាប់វិញ អំណះអំណាងនេះគ្រាន់តែជាឧបាយកលមួយដើម្បីពន្យារពេលនីតិវិធីតែប៉ុណ្ណោះ។

## III. អង្គជំនុំជម្រះសាលាដំបូងពុំគួរកែប្រែកាលបរិច្ឆេទ ដែលការផុតកំណត់ នៃការដាក់អញ្ញត្រកម្ម អនុលោមតាមវិធាន ៨៩ បានចាប់ផ្តើមនោះឡើយ

៤. វិធាន ៨៩ នៃវិធានផ្ទៃក្នុងចែងថាអញ្ញត្រកម្មត្រូវលើកឡើង "យ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ ក្រោយពីដីកាដំណោះស្រាយចូលជាស្ថាពរ"។ ដោយអនុវត្តតាមកាលបរិច្ឆេទដែលអង្គជំនុំជម្រះសាលាដំបូងបានកំណត់ថាជាថ្ងៃជាស្ថាពរនៃដីកាដំណោះស្រាយ រយៈពេលផុតកំណត់ ៣០ថ្ងៃ នៃការដាក់អញ្ញត្រកម្ម ចាប់គិតពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១[8]។

៥. ក្រុមមេធាវីការពារក្តីអះអាងថារយៈពេល ៣០ ថ្ងៃ ពុំទាន់ចាប់ផ្តើមរាប់ឡើយ ដោយហេតុថា សាលដីការបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ពុំមានសំអាងហេតុគ្រប់គ្រាន់ ហើយដូច្នេះសាលដីកានេះពុំទាន់មានអានុភាពជា "សេចក្តីសម្រេច" ឡើយ[9]។ អំណះអំណាងនេះពុំសមហេតុផល ហើយមានវិការៈដោយសារសកម្មភាព និងការទទួលស្គាល់ការពិតរបស់ខ្លួន។ ជាការពិត តាមរយៈការដាក់ឯកសារផ្សេងៗជូនអង្គជំនុំជម្រះសាលាដំបូង ក្រុមមេធាវីការពារក្តីបានទទួលស្គាល់ទាំងស្រុងថា សាលដីការបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ គឺជា "សាលដីកា" ដែលមានសុពលភាព សម្រាប់គោលបំណង

---

[8] *សូមមើល* អង្គជំនុំជម្រះសាលាដំបូង, ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ, ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១, កថាខណ្ឌ ២ (ដែលបានយល់ឃើញពាក់ព័ន្ធនឹងបញ្ញត្តិមួយទៀតដែលយោងទៅលើ "ថ្ងៃដែលដីកាដំណោះស្រាយចូលជាស្ថាពរ" ថារយៈពេលកំណត់នេះត្រូវចាប់គិតពីថ្ងៃសុក្រ ទី១៤ ខែមករា ឆ្នាំ២០១១ ដោយផ្អែកលើមូលដ្ឋានដែលថា កាលបរិច្ឆេទនេះ "ជាថ្ងៃដែលក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿងជាផ្លូវការពីអង្គបុរេជំនុំជម្រះ")។
[9] បណ្តឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្តី, កថាខណ្ឌ ៤-៥។

នៃវិធាននេះ[10]។ ជាការសមហេតុផល ប្រសិនបើសាលដីកានេះពុំមានសុពលភាព សាលដីកានេះពុំអាចធ្វើឱ្យមានដំណើរការបញ្ជូនសំណុំរឿងទៅឱ្យអង្គជំនុំជម្រះសាលាដំបូងឡើយ។

៦. បន្ថែមលើនេះទៀត នឹងមិនមានការខូចខាតប្រយោជន៍ដល់មេធាវីការពារក្តី ហើយក៏មិនមានការរំលោភបំពានទៅលើ ICCPR ដែរ ប្រសិនបើតម្រូវឱ្យមេធាវីការពារក្តី គោរពទៅតាមពេលវេលាកំណត់ដូចបានរៀបរាប់ពីខាងដើមនោះ ទោះបីជា ទង្វើនេះបង្ហាញថា ជាការលើកឡើងអញ្ញត្រកម្មមុនពេលអង្គបុរេជំនុំជម្រះដាក់ចេញនូវសំអាងហេតុលម្អិតរបស់ខ្លួន ក៏ដោយ។ ពាក់ព័ន្ធនឹងបញ្ហាយុត្តាធិការ ដែលមេធាវីការពារក្តីបានលើកឡើង អង្គជំនុំជម្រះសាលាដំបូងមិនមានកាតព្វកិច្ចត្រូវប្រតិបត្តិតាមការយល់ឃើញរបស់អង្គបុរេជំនុំជម្រះនោះទេ ហើយមិនមានហេតុផលណាមួយ ដែលបង្ហាញថា សេចក្តីសម្រេចពេញលេញរបស់អង្គបុរេជំនុំជម្រះនឹងធ្វើឱ្យប៉ះពាល់ដល់អញ្ញត្រកម្មរបស់ជនត្រូវចោទ ដែលនឹងត្រូវធ្វើឡើងនៅចំពោះមុខអង្គជំនុំជម្រះនោះ យ៉ាងដូចម្តេចនោះទេ។ ជាក់ស្តែង សហព្រះរាជអាជ្ញា យល់ឃើញថា មិនថាចំណុចជាក់លាក់នៃសំអាងហេតុ ដែលនឹងត្រូវផ្តល់នៅក្នុងសេចក្តីសម្រេចពេញលេញរបស់អង្គបុរេជំនុំជម្រះ នាពេលខាងមុខនេះ ជាអ្វីក៏ដោយនោះទេ ក៏មេធាវីការពារក្តីទំនងនឹងលើកឡើងនូវបញ្ហាអញ្ញត្រកម្ម ដូចៗគ្នានេះ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដដែល។

៧. គ្មានមូលដ្ឋានសមស្របច្បាស់លាស់ណាមួយ ចំពោះការស្នើសុំរបស់មេធាវីការពារក្តី ដែលលើកឡើងថា ពេលវេលាកំណត់ដូចបានរៀបរាប់ខាងលើ នឹងធ្វើឱ្យមានផលប៉ះពាល់ដល់សិទ្ធិរបស់ពួកគាត់ ក្នុងការទទួលបាននូវ "ពេលវេលា និងមធ្យោបាយគ្រប់គ្រាន់" ក្នុងការរៀបចំ

---

[10] នួន ជា បានទទួលស្គាល់យ៉ាងច្បាស់នូវចំណុចនេះ។ *សូមមើល* សំណើសុំដោះលែង នួន ជា ជាបន្ទាន់, កថាខណ្ឌ ១១ (ដែលបានទទួលស្គាល់ថាអង្គជំនុំជម្រះសាលាដំបូងបានដឹងអំពីសំណុំរឿងនេះ "ដោយសារសាលដីការបស់ អ.ប.ជ កាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១") (គូសបញ្ជាក់បន្ថែម)។

អញ្ញត្រកម្មនានា របស់ពួកគាត់[11]។ ក្រុមមេធាវីការពារក្ដី អៀង ធីរិទ្ធ និងក្រុមមេធាវីការពារក្ដី នួន ជា គឺជាអ្នកសកម្មក្នុងការលើកឡើងបញ្ហាគតិយុត្តិនានា នៅក្នុងដំណាក់កាលមុនសវនាការ ហើយក្នុងនាមជាមេធាវីការពារក្ដីដែលឧស្សាហ៍ព្យាយាម ពួកគាត់បានលះបង់ពេលវេលាដ៏សំខាន់ ក្នុងរយៈពេលបីឆ្នាំកន្លងមកនេះ ដោយមិនមានការរារែក ដើម្បីស្រាវជ្រាវ និងរៀបចំអញ្ញត្រកម្មនានា ដែលមានប្រយោជន៍សម្រាប់កូនក្ដីរបស់ខ្លួន។ ជាក់ស្ដែង កម្រិតនៃការរៀបចំរបស់ក្រុមមេធាវីការពារក្ដីនេះ ត្រូវបានស្ដែងឡើងតាមរយៈគុណភាពនៃសារណានានា ដែលពួកគាត់បានដាក់ជូនអង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍ ជំទាស់នឹងដីកាដំណោះស្រាយ។ ទោះបីជានៅក្នុងករណីណាក៏ដោយ សិទ្ធិក្នុងការទទួលបាន "ពេលវេលា និងមធ្យោបាយគ្រប់គ្រាន់" ត្រូវតែធ្វើឱ្យមានតុល្យភាព ជាមួយនឹងសមាសធាតុសំខាន់ចាំបាច់មួយទៀត នៃសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះដោយយុត្តិធម៌ នោះគឺសិទ្ធិរបស់ចុងចោទក្នុងការទទួលបាននូវការជំនុំជម្រះ ដោយមិនមានការពន្យារពេលមិនសមស្រប[12]។

៨. ប៉ុន្តែ ទោះបីជាសហព្រះរាជអាជ្ញានៅតែអះអាងថា មិនមានការចាំបាច់សម្រាប់ឱ្យជនជាប់ចោទលើកឡើងសំអាងហេតុលម្អិតរបស់អង្គបុរេជំនុំជម្រះ នៅក្នុងសារណារបស់ខ្លួន ស្ដីពីអញ្ញត្រកម្ម ដោយពិចារណាដល់ភាពមិនលម្អៀង ល្បឿន និងការសន្សំសំចៃរបស់តុលាការក៏ដោយ ក៏សហព្រះរាជអាជ្ញា នឹងមិនជំទាស់ចំពោះការដាក់ជូននូវសារណាបន្ថែមរបស់មេធាវីការពារក្ដី បន្ទាប់ពីអង្គបុរេជំនុំជម្រះ ដាក់ចេញនូវសេចក្ដីសម្រេចពេញលេញនោះទេ ដរាបណា ការពិភាក្សានៅក្នុងសារណាបន្ថែមនោះ <u>បានលើកឡើងចំៗ</u> ទៅនឹងសំអាងហេតុជាក់លាក់ ដែលមានចែងនៅក្នុងសេចក្ដីសម្រេចពេញលេញរបស់អង្គបុរេជំនុំជម្រះ។

---

[11] សំណើរបស់ក្រុមមេធាវីការពារក្ដី, កថាខណ្ឌ៦-៧ (យោងមាត្រា១៤(៣) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ)។

[12] ICCPR មាត្រា១៤(៣)(គ)។ ច្បាប់ស្ដីពីការបង្កើតអ.វ.ត.ក មាត្រា៣៣ (ថ្មី)។

*សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ*

## IV. សេចក្ដីសន្និដ្ឋាន

៩. យោងសំអាងហេតុដូចបានរៀបរាប់ពីខាងដើម សហព្រះរាជអាជ្ញា សូមគោរពស្នើសុំឱ្យ៖

(១) អង្គជំនុំជម្រះសាលាដំបូង សម្រេចថា សំណើចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១ សុំឱ្យបញ្ជាក់កាលបរិច្ឆេទផុតកំណត់ដើម្បីរៀបចំបញ្ជីឈ្មោះសាក្សីតាមវិធាន៨០ របស់មេធាវីការពារក្ដីនោះគឺមិនចាំបាច់នោះទេ ដោយអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់រួចហើយថា កាលបរិច្ឆេទផុតកំណត់ដែលត្រូវអនុវត្តនោះគឺ ចាប់ផ្ដើមពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១។

(២) អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យមេធាវីការពារក្ដី ដាក់អញ្ញត្រកម្មរបស់ខ្លួនតាមវិធាន៨៩ មិនឱ្យហួសរយៈពេល៣០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការចូលជាស្ថាពរនៃដីកាដំណោះស្រាយ ពោលគឺថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១។

សូមលោកចៅក្រមទទួលនូវក្ដីគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ២៥ មករា ២០១១ | លោក យ៉េត ចរិយា<br>សហព្រះរាជអាជ្ញារង | ភ្នំពេញ | [signature] |
| | Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |